Forte
General Insurance



# ការធានារ៉ាប់រងគ្រឿងចក្រ និងគ្រឿងម៉ាស៊ីនសាងសង់

## ខនិងលក្ខខ័ណ្ឌសង្ខេប

សម្រាប់គ្រឿងចក្រឬគ្រឿងម៉ាស៊ីន (ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) ដែលជាចលនវត្ថុ ក្រោមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ នៃ**អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី**

## វិសាលភាពនៃការធានារ៉ាប់រង៖

### ១. ភារៈទទួលខុសត្រូវតាមផ្លូវច្បាប់លើតតិយជន (ភាគីទីបី) ៖

ហ្វតេ ផ្តល់នូវការធានាលើការចំណាយដែលលោកអ្នកមានភារៈទទួលខុសត្រូវតាមផ្លូវច្បាប់ តាមកម្រិតនៃសំណងធានារ៉ាប់រងខាងក្រោម ដែលបណ្តាលមកពីគ្រោះថ្នាក់ដែលបង្កឬកើតឡើងដោយ ការប្រើប្រាស់គ្រឿងចក្រឬគ្រឿងម៉ាស៊ីន (ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) ដែលត្រូវបានធានារ៉ាប់រង របស់លោកអ្នក សម្រាប់៖

- ការបង្កឱ្យបាត់បង់ជីវិត ឬរបួសរូបរាងកាយរបស់តតិយជន
- ការបង្កឱ្យខូចខាតទ្រព្យសម្បត្តិរបស់តតិយជន

កម្រិតនៃសំណងធានារ៉ាប់រង ៖

- អតិបរមា ១០,០០០ ដុល្លារអាមេរិក ក្នុងម្នាក់ និងក្នុងមួយករណី សម្រាប់មរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ ឬរបួសស្នាមលើរូបរាងកាយរបស់តតិយជន
- អតិបរមា ១០,០០០ ដុល្លារអាមេរិក ក្នុងម្នាក់ និងក្នុងមួយករណី សម្រាប់ការខូចខាតទ្រព្យសម្បត្តិរបស់តតិយជន
- អតិបរមា ១,៥០០ ដុល្លារអាមេរិក ក្នុងមួយករណីសម្រាប់សេវាផ្នែកច្បាប់
- អតិបរមា ១០០,០០០ ដុល្លារអាមេរិក ក្នុងមួយករណីគ្រោះថ្នាក់ ឬច្រើនករណីគ្រោះថ្នាក់ ក្នុងរយៈពេលធានារ៉ាប់រងមួយឆ្នាំ សម្រាប់សំណងធានារ៉ាប់រងសរុប ។

កម្រិតមិនទូទាត់សំណង (ចំនួនដែលជាទំនួលខុសត្រូវរបស់លោកអ្នក)៖

- ៣% នៃចំនួនទឹកប្រាក់ទាមទារសំណង ក្នុងមួយករណី សម្រាប់គ្រឿងចក្រឬគ្រឿងម៉ាស៊ីន (ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) ដែលបានធានារ៉ាប់រង ១គ្រឿង។
  (សម្រាប់តែការទាមទារសំណងលើការខូចខាតទ្រព្យសម្បត្តិរបស់តតិយជនតែប៉ុណ្ណោះ។)

សំណងធានារ៉ាប់រង នឹងត្រូវដកចេញនូវកម្រិតមិនទូទាត់សំណង ដូចមានចែងខាងលើ។

### ២. ចោរកម្ម ការខូចខាតទាំងស្រុង និងការខូចខាត ទាំងស្រុងតាមការសន្មត)៖

ហ្វតេ ផ្តល់នូវការធានាលើការបាត់បង់ ឬខូចខាតលើគ្រឿងចក្រឬគ្រឿងម៉ាស៊ីន (ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) ដែលត្រូវបានធានារ៉ាប់រង របស់លោកអ្នក ដែលបណ្តាលមកពី៖
**ទឹកជំនន់ ព្យុះ រញ្ជួយដី ការផ្ទុះមីន** និង**ចោរកម្ម** (ចោរគាស់ ចោរលួច ចោរប្លន់ នៃគ្រឿងចក្រឬគ្រឿងម៉ាស៊ីន (ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) ទាំងមូល) ដែលកើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។

កម្រិតនៃសំណងធានារ៉ាប់រង ៖

- ប្រសិនបើទឹកប្រាក់ធានារ៉ាប់រងតូចជាង ឬស្មើ ៦០% នៃតម្លៃគ្រឿងចក្រឬគ្រឿងម៉ាស៊ីន(ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) នោះគ្រឿងចក្រឬគ្រឿងម៉ាស៊ីន(ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) នោះនឹងនៅតែជាកម្មសិទ្ធរបស់លោកអ្នក។
- ប្រសិនបើទឹកប្រាក់ធានារ៉ាប់រងច្រើនជាង ៦០% នៃតម្លៃគ្រឿងចក្រឬគ្រឿងម៉ាស៊ីន (ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) នោះលោកអ្នកត្រូវប្រគល់កម្មសិទ្ធគ្រឿងចក្រឬគ្រឿងម៉ាស៊ីន(ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ)នោះ មកកាន់ហ្វតេ ដោយប្រគល់អោយហ្វតេនូវឯកសារពាក់ព័ន្ធទាំងឡាយផងដែរ។

កម្រិតមិនទូទាត់សំណង (ចំនួនដែលជាទំនួលខុសត្រូវរបស់លោកអ្នក)៖

- ៣% នៃចំនួនទឹកប្រាក់ទាមទារសំណង ក្នុងមួយករណី សម្រាប់គ្រឿងចក្រឬគ្រឿងម៉ាស៊ីន (ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) ដែលបានធានារ៉ាប់រង ១គ្រឿង។

សំណងធានារ៉ាប់រង នឹងត្រូវដកចេញនូវកម្រិតមិនទូទាត់សំណង ដូចមានចែងខាងលើ។

**សំណងច្រើនបំផុតសម្រាប់ករណីខាងលើ គឺស្មើនឹងទឹកប្រាក់ធានារ៉ាប់រងដែលជាប្រាក់ប្រាតិភោគ(ចំនួនកម្ចី)ដែលលោកអ្នកបានព្រមព្រៀងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុជាមួយអិលអូអិលស៊ី ។**

**ចំណាំ៖**

- ការខូចខាតផ្នែកណាមួយនៃគ្រឿងចក្រ ឬគ្រឿងម៉ាស៊ីន(ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) មិនត្រូវបានធានាក្នុងបណ្ណសន្យារ៉ាប់រងដែលបានព្រមព្រៀងដោយហ្វតេនិងអិលអូអិលស៊ី នេះទេ)។
- **ការខូចខាតទាំងស្រុង៖** សំដៅដល់ការខូចខាតទាំងស្រុងដែលមិនអាចជួសជុលបាន។
- **ការខូចខាតទាំងស្រុងតាមការសន្មត៖** សំដៅដល់ករណីដែលការចំណាយលើការជួសជុលការខូចខាតគ្រឿងចក្រឬគ្រឿងម៉ាស៊ីន(ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) មានទំហំស្មើ ឬច្រើនជាង ៧០% នៃតម្លៃគ្រឿងចក្រឬគ្រឿងម៉ាស៊ីន (ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ) នោះ នៅពេលលោកអ្នកទទួលយកនូវភតិសន្យាហិរញ្ញវត្ថុ(កម្ចី) ពីអិលអូអិលស៊ី ។

## ករណីមិនធានា៖

**ហ្វតេនឹងមិនទូទាត់សំណងធានារ៉ាប់រងឡើយ លើរាល់គ្រោះថ្នាក់ ការបាត់បង់ ការខូតខាត និងភារៈទទួលខុសត្រូវតាមផ្លូវច្បាប់(ដោយផ្ទាល់ ឬមិនផ្ទាល់ក្តី) ដែល៖**

១. លោកអ្នកមិនបានរាយការណ៍ដល់ហ្វតេក្នុងរយៈពេល២៤ម៉ោង ក្រោយពេលកើតហេតុ។
២. លោកអ្នកមិនបានរាយការណ៍ដល់សមត្ថកិច្ចមូលដ្ឋាន សម្រាប់ការបាត់បង់ដោយចោរកម្ម។
៣. គ្រោះថ្នាក់នោះកើតឡើងនៅក្រៅទីតាំងភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។
៤. គ្រោះថ្នាក់នោះកើតឡើង៖

- ខណៈអ្នកបើកបរ មានប្រើប្រាស់គ្រឿងញៀន ឬបើកបរស្ថិតនៅក្រោមសារជាតិស្រវឹង (យោងតាមរបាយការណ៍បញ្ជាក់របស់សមត្ថកិច្ចចរាចរណ៍ និងច្បាប់ចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា)។
- ការបើកបរដោយអ្នកបើកបរដែលគ្មានការអនុញ្ញាតបើកបរពីអ្នកត្រូវបានធានារ៉ាប់រង។
- ខណៈអ្នកបើកបរ មិនមានប័ណ្ណបើកបរ ឬមានប័ណ្ណបើកបរដែលខុសប្រភេទយានយន្ត ឬដែលផុតសុពលភាព នៅពេលមានគ្រោះថ្នាក់។(ប័ណ្ណបើកបរដែលមានសុពលភាពគឺជាប័ណ្ណបើកបរដែលមិនទាន់ផុតកំណត់ ត្រូវតាមប្រភេទយានយន្ត និងត្រូវតាមច្បាប់ចំពោះអាយុរបស់អ្នកបើកបរ។
- ខណៈដែលលោកអ្នកដោះស្រាយសំណងដោយខ្លួនឯង ហើយគ្មានការយល់ព្រមឬឯកភាពពីក្រុមដោះស្រាយសំណង ហ្វតេ ជាមុន។

៥. ភារៈទទួលខុសត្រូវតាមផ្លូវច្បាប់នោះ ជាភារៈទទួលខុសត្រូវដែលលោកអ្នកបានយល់ព្រមក្រោមកិច្ចសន្យាណាមួយ ដែលលោកអ្នកមិនមានភារៈទទួលខុសត្រូវនោះទេ ប្រសិនបើគ្មានកិច្ចសន្យាមួយនោះ។
៦. ការខូចខាតឬបាត់បង់គ្រឿងចក្រឬគ្រឿងម៉ាស៊ីនដែលត្រូវបានធានា ដែលបណ្តាលមកពី៖
   - សង្គ្រាម ការលុកលុយ សកម្មភាពរបស់សត្រូវបរទេស អរិភាព ឬប្រតិបត្តិការនៃសង្គ្រាម (ថាតើសង្គ្រាមបានប្រកាស ឬអត់) សង្គ្រាម ស៊ីវិល សកម្មភាពប្រយុទ្ធបដិវត្ត ការបះបោរ កុបកម្ម កូដកម្ម ការឃុំឃាំង ការរឹបអូស ឬការប៉ុនប៉ងណាមួយ ដែលគំរាមកំហែង ដល់កម្លាំងយោធា ឬអំណាចដណ្តើមអំណាចប្រឆាំងនឹងរាជរដ្ឋាភិបាល ការធ្វើរដ្ឋប្រហារ ឬបើមិនដូច្នោះទេ ការកោលាហលស៊ីវិល។
   - ការប្រើប្រាស់អាវុធនុយក្លេអ៊ែរ។
   - ការបែកខ្ញែកវិទ្យុសកម្ម វិទ្យុសកម្មអ៊ីយ៉ូដ ផលប៉ះពាល់វិទ្យុសកម្មពី ឥន្ធនៈនុយក្លេអ៊ែរ ឬពីកាកសំណល់នុយក្លេអ៊ែរ ណាមួយពីការ ឆេះឥន្ធនៈនុយក្លេអ៊ែរចំហេះ ដែលសំដៅទៅលើការបែកបាក់នៃការប្រជុំគ្នាដោយវិទ្យុសកម្មដោយខ្លួនឯង។
   - ការខូចម៉ាស៊ីនឬប្រព័ន្ធភ្លើង ប្រេងរំអិលឬទឹកត្រជាក់ដែលកក ការប្រើប្រេងរំអិលដែលខូចគុណភាព កង្វះប្រេងរំអិលឬទឹកត្រជាក់ក្នុង គ្រឿងចក្រឬគ្រឿងម៉ាស៊ីន ។
   - ការផ្ទុះម៉ាស៊ីនប្រើចំហាយ។
   - យានយន្តដែលមានសិទ្ធបើកលើផ្លូវ យាន្តសម្រាប់ប្រើលើឬក្នុងទឹក ។
   - ការខូចខាតគ្រឿងចក្រឬគ្រឿងម៉ាស៊ីនក្នុងអំឡុងពេលដែលត្រូវបានគេដឹកជញ្ជូន។
   - ការខូចខាតដែលកើតពី ការបន្តធ្វើសកម្មភាព (ឧទាហរណ៍ ការសឹកវិចរិល ការច្រេះ ភាពចុះខ្សោយនៃគុណភាពដោយសារការទុកចោលមិនមានការប្រើប្រាស់ និងដោយសារស្ថានភាពបរិយាកាសធម្មតា។
   - ការខូចខាតដែលកើតពី ការបន្តធ្វើសកម្មភាព (ឧទាហរណ៍ ការសឹកវិចរិល ការច្រេះ ភាពចុះខ្សោយនៃគុណភាពដោយសារការទុកចោលមិនមានការប្រើប្រាស់ និងដោយសារស្ថានភាពបរិយាកាសធម្មតា។
   - នៅពេលដែលគ្រឿងចក្រឬគ្រឿងម៉ាស៊ីន៖
     - ត្រូវបានគេធ្វើការសាកល្បង
     - ត្រូវបានប្រើប្រាស់សម្រាប់ការងារផ្សេងខុសពីមុខងារដើម
     - ត្រូវបានប្រើប្រាស់សម្រាប់ការងារក្រោមដី
   - កំហុសបច្ចេកទេសនៃគ្រឿងចក្រឬគ្រឿងម៉ាស៊ីន។
   - ការធ្វើអោយមានការខូចខាតដោយបំណង ឬ ដោយការធ្វេសប្រហែសដោយបំណងអាក្រក់របស់អ្នកត្រូវបានធានារ៉ាប់រងឬអ្នកតំណាងរបស់គាត់។
   - ការខូចខាតឬបាត់បង់ដែលក្រុមហ៊ុន/អង្គភាពផលិត ឬផ្គត់ផ្គង់ត្រូវទទួលខុសត្រូវតាមច្បាប់។
   - ការខូចខាតឬភារៈទទួលខុសត្រូវដែល ជាផលវិបាកកើតឡើងពីការខូចខាតណាមួយ។
   - ការខូចខាតឬបាត់បង់ដែលត្រូវបានរកឃើញពេលត្រួតពិនិត្យថែទាំគ្រឿងចក្រឬគ្រឿងម៉ាស៊ីន។

(នេះជាករណីមិនធានាចំបងៗតែប៉ុណ្ណោះ។) សម្រាប់ករណីមិនធានាទាំងស្រុង សូមអានបណ្ណសន្យារ៉ាប់រងលម្អិត នៃការធានារ៉ាប់រងគ្រឿងចក្រ និងគ្រឿងម៉ាស៊ីនសាងសង់ ដោយស្កេន QR៖

សម្រាប់ការសាកសួរព័ត៌មានបន្ថែម សូមទាក់ទងទូរស័ព្ទលេខ៖

**០១២ ២០២ ១១១**
**០៩៥ ៦៦៦ ៥១៨**

បណ្ណសន្យារ៉ាប់រងគ្រឿងចក្រ និងគ្រឿងម៉ាស៊ីនសាងសង់ នេះត្រូវបានធានារ៉ាប់រងដោយ **ក្រុមហ៊ុន ហ្វតតេ អ៊ិនស្ទួរ៉ិនស៍ (ខេមបូឌា)**

## នីតិវិធីនៃការទាមទារសំណងធានារ៉ាប់រង

ក្នុងពេលមានហេតុការណ៍គ្រោះថ្នាក់ចៃដន្យ ឬការខូចខាត ឬការបាត់បង់លើគ្រឿងចក្រឬគ្រឿងម៉ាស៊ីន(ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ)លោកអ្នកត្រូវ៖

ផ្តល់ដំណឹង ភ្លាមៗមកកាន់ ហ្វតតេ តាមរយៈលេខទូរស័ព្ទបន្ទាន់ (២៤/៧)
**០៩៥ ៥៥៥ ៣២៨**

(បុគ្គលិកទទួលបន្ទុកដោះស្រាយសំណងធានារ៉ាប់រង របស់ហ្វតតេនឹងនៅចាំផ្តល់សេវាកម្មជូនលោកអ្នក២៤ម៉ោងជារៀងរាល់ថ្ងៃ រួមទាំងថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃបុណ្យជាតិផ្សេងៗផងដែរ។)

ដើម្បីសម្រួលដល់ដំណើរការដោះស្រាយសំណងធានារ៉ាប់រង សូមលោកអ្នកផ្តល់ព័ត៌មាន ដូចខាងក្រោម៖

- ឈ្មោះអ្នកដែលត្រូវបានធានារ៉ាប់រង
- ប្រភេទគ្រឿងចក្រឬគ្រឿងម៉ាស៊ីន
- ពេលវេលា និងទីតាំងកើតហេតុ
- អង្គហេតុគ្រោះថ្នាក់ ឬការខូចខាត
- លេខទំនាក់ទំនង

* សម្រាប់ការទាមទារសំណងធានារ៉ាប់រងលើការបាត់បង់ ដោយសារចោរកម្ម (ចោរគាស់ ចោរលួច ចោរប្លន់) លោកអ្នកត្រូវផ្តល់ដំណឹងភ្លាមៗ (ដាក់ពាក្យបណ្តឹង) ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចប្រចាំតំបន់កើតហេតុ។

**សូមផ្ញើឯកសារខាងក្រោមមកកាន់ហ្វតតេតាមរយៈមធ្យោបាយខាងក្រោម អោយបានឆាប់បំផុត ឬក្នុងរយៈពេល១៤ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុ៖**

- ពាក្យស្នើសុំទាមទារសំណងធានារ៉ាប់រង
- សម្រង់តម្លៃនៃការជួសជុលឬផ្លាស់ប្តូរគ្រឿងចក្រឬគ្រឿងម៉ាស៊ីន (ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ)
- របាយការណ៍ប៉ូលីស និង/ឬ របាយការណ៍ពីកងពន្លត់អគ្គិភ័យ (ប្រសិនបើមាន)
- លិខិតទាមទារសំណងជាលាយលក្ខណ៍អក្សររបស់ភាគីទីបី (ប្រសិនបើមាន)
- គ្រឿងចក្រឬគ្រឿងម៉ាស៊ីន (ឧបករណ៍ធុនធ្ងន់ ឬត្រាក់ទ័រ)
- កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុជាមួយអិលអូអិលស៊ី ដែលមានភ្ជាប់មកជាមួយនូវតារាងនៃការបង់ប្រាក់(ថ្លៃឈ្នួល)
- ឯកសារផ្សេងទៀតដែលអាចត្រូវបានតម្រូវដោយ ហ្វតតេ

**ចំណាំ ៖**

- ពេលមានគ្រោះថ្នាក់ លោកអ្នកមិនត្រូវទទួលកំហុស ឬសន្យាធ្វើសំណងឬបង់ប្រាក់អ្វីមួយដោយគ្មានការណែនាំឬព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនពី ហ្វតតេ ឡើយ។ **បើមិនដូច្នោះ លោកអ្នកអាចនឹងមិនទទួលបានសំណងធានារ៉ាប់រង ពីការធានានៃបណ្ណសន្យារ៉ាប់រងឡើយ។**
- លោកអ្នកត្រូវផ្តល់កិច្ចសហការណ៍ជាមួយ ហ្វតតេ ក្នុងការទាមទារសំណងធានារ៉ាប់រងនៃគ្រោះថ្នាក់នីមួយៗ។

**សម្រាប់ការជូនដំណឹងពីការទាមទារសំណងធានារ៉ាប់រង សូមទំនាក់ទំនងទៅកាន់ទូរស័ព្ទបន្ទាន់ (២៤/៧) លេខ ០៩៥ ៥៥៥ ៣២៨**

**នីតិវិធីនៃការទាមទារសំណងធានារ៉ាប់រង និង**
**ពាក្យស្នើសុំទាមទារសំណងធានារ៉ាប់រង**
សូមស្កេន៖